**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

*ថ្ងៃ សុក្រ ១២ រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២៣*

# សេចក្ដីប្រកាសព័ត៌មាន
## ក្នុងសិក្ខាសាលាអន្តរជាតិស្ដីពី
## “ការតម្រឹមនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ទាំងស្រុង និង ការគ្រប់គ្រងការផ្លាស់ប្ដូរ”

នៅព្រឹកថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២៣, ក្រោមកិច្ចសហការជាមួយធនាគារពិភពលោក, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាអន្តរជាតិស្ដីពី **“ការតម្រឹមនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ Financial Management Information System - “FMIS” ទាំងស្រុង និង ការគ្រប់គ្រងការផ្លាស់ប្ដូរ”** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នទាំងអស់ រួមជាមួយតំណាងដៃគូអភិវឌ្ឍន៍ ទាំងនៅកន្លែងប្រារព្ធពិធីផ្ទាល់ និងតាមប្រព័ន្ធវីដេអូអនឡាញ សរុបចំនួនប្រមាណ ៤០០ រូប ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានចក្ខុវិស័យក្នុងការប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈផ្ដោតលើលទ្ធផល ឬ សមិទ្ធកម្ម និង វិមជ្ឈការ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ ខណៈដែលប្រព័ន្ធ FMIS គឺជាឧបករណ៍ស្នូលដែលពុំអាចខ្វះបានសម្រាប់ជួយគាំទ្រ និងជំរុញដល់ការសម្រេចគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពទាន់ពេលក្នុងការទទួលបានទិន្នន័យ និង ព័ត៌មាននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ការចាប់ផ្ដើមអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង បាននិងកំពុងរួមចំណែកយ៉ាងធំធេង និងបង្ហាញយ៉ាងច្បាស់ថា ប្រព័ន្ធពិតជាបានផ្ដល់នូវមូលដ្ឋានជាក់លាក់ ក្នុងការជំរុញការអនុវត្តនីតិវិធីឱ្យកាន់តែបានលឿនបន្ថែមមួយកម្រិតទៀតសម្រាប់ការអនុវត្តចំណាយថវិកា ដែលបច្ចុប្បន្នត្រូវចំណាយពេល និងធនធានច្រើនក្នុងការអនុវត្ត ជាពិសេសរំហូរនៃដំណើរការបញ្ជូនឯកសារជាក្រដាសពីដំណាក់កាលមួយទៅដំណាក់កាលមួយ ឬពីកន្លែងមួយទៅកន្លែងមួយ ដែលផ្ដល់នូវភាពលំបាកនិងភាពស្មុគស្មាញសម្រាប់ការតាមដានស្ថានភាពនៃឯកសារ, ហើយក្នុងករណីមានកំហុសឆ្គងម្ដងៗ ត្រូវរុញឯកសារត្រលប់កែតម្រូវចុះឡើងៗ ដែលកាន់តែធ្វើឱ្យមានភាពយឺតយ៉ាវ ។

ការអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុងនេះ គឺជាចំណែកនៃគន្លងការងារថ្មីរបស់រាជរដ្ឋាភិបាល ស្របតាមក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ហេតុនេះ មន្ត្រីរាជការត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់ ក្នុងការរៀនសូត្របន្ថែម និង ចាប់យកឱ្យបាននូវការផ្លាស់ប្តូររបៀបធ្វើការងារថ្មី បង្កើនភាពស៊ាំឱ្យបានលឿន តាមឱ្យទាន់កាលៈទេសៈនៃការវិវឌ្ឍសង្គម និង សេដ្ឋកិច្ចឌីជីថល ។ ថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់ជាន់ថ្នាក់ ដែលមានតួនាទី ភារកិច្ច ក្នុងការបំពេញកិច្ចការថវិកា និង ហិរញ្ញវត្ថុ ត្រូវត្រៀមខ្លួនក្នុងការផ្លាស់ប្តូរនូវរបត់ការងារជានិច្ច និង បំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ប្រកបដោយវិជ្ជាជីវៈ និង ត្រូវគិតជាធំទៅលើប្រសិទ្ធភាពថវិកា ជាពិសេសការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ **កម្មវិធីតាមដាន និងត្រួតពិនិត្យស្ថានភាពប្រតិបត្តិការហិរញ្ញវត្ថុ និងការអនុវត្តថវិកា**នៅក្នុងប្រព័ន្ធ FMIS និង ដាក់ឱ្យអនុវត្តបន្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុងជាផ្លូវការ នៅឆ្នាំ ២០២៣ នេះ សម្រាប់ការអនុវត្តនីតិវិធី៖

១. **ចំណាយថវិកាចរន្តគ្រប់មុខសញ្ញា** តាមប្រព័ន្ធទាំងស្រុង ដោយយកលំនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន សម្រាប់ក្រសួង-ស្ថាប័នចំនួន ៦ ថ្មី រួមមាន ក្រសួងរ៉ែ និង ថាមពល, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងយុត្តិធម៌, ក្រសួងធម្មការនិងសាសនា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អាជ្ញាធរសវនកម្មជាតិ ។

២. **ចលនាឥណទានចំណាយថវិកាចរន្ត** តាមប្រព័ន្ធ FMIS ទាំងស្រុង នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន និង ក្រសួងទាំង៦ ខាងលើ ។

៣. **ចំណាយថវិកាចរន្តដែលមិនមានធានាចំណាយដោយឡែក** តាមប្រព័ន្ធ FMIS ទាំងស្រុង នៅក្រសួងចំនួន ៧ និង អង្គភាពថវិការបស់ខ្លួន រួមមាន ក្រសួងសុខាភិបាល, ក្រសួងផែនការ, ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងមុខងារសធារណៈ និង ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រនិងនវានុវត្តន៍ ។

នៅទីបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានថ្លែងអំណរគុណ និង វាយតម្លៃខ្ពស់ចំពោះការចូលរួមចំណែករបស់តំណាងដៃគូអភិវឌ្ឍន៍, ក្រសួងហិរញ្ញវត្ថុរបស់សាធារណរដ្ឋឥណ្ឌូនេស៊ី ក្រសួងហិរញ្ញវត្ថុនៃរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតឡាវ និង ភ្នាក់ងារអភិវឌ្ឍន៍បារាំងក្នុងការចែករំលែកបទពិសោធន៍របស់ខ្លួន នៃការតម្រឹមនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង និង ការគ្រប់គ្រងការផ្លាស់ប្តូរតាមរយៈអង្គសិក្ខាសាលានេះ ។ ទន្ទឹមនឹងនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ក៏បានមូលវាចារណ៍ដ៏ថ្លៃថ្លា ចំពោះការបន្តគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេសរបស់សហភាពអឺរ៉ុប, ធនាគារពិភពលោក និង រដ្ឋាភិបាលអូស្ត្រាលីក្នុងការរៀបចំឱ្យអង្គសិក្ខាសាលាដ៏សំខាន់នេះ ប្រព្រឹត្តិទៅបានដោយរលូន ព្រមទាំងសង្ឃឹមថានឹងទទួលបានកិច្ចសហការជាបន្តបន្ទាប់ទៀតដើម្បីរៀបចំឱ្យមាននូវកម្មវិធី និង ព្រឹត្តិការណ៍បែបនេះ ដើម្បីជួយជំរុញដល់ការយល់ដឹងឱ្យកាន់តែជ្រួតជ្រាបច្បាស់ ពាក់ព័ន្ធកែលម្អនីតិវិធី, វិបុលនៃការអនុវត្តការងារ និង ការអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង និងកម្មវិធីផ្សេងៗទៀតក្នុងក្របខណ្ឌការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ។